# សេចក្តីជូនដំណឹងស្តីពីសិទ្ធ និងការការពារផលប្រយោជន៍របស់អ្នកទទួលផលដោយគ្មានភាពរើសអើង

*<u>ការការពារផលប្រយោជន៍ "ដោយគ្មានភាពរើសអើង/ ជំពូកទី6" របស់សហព័ន្ធ</u>*

មន្ទីរគមនាគមន៍នៃរដ្ឋម៉ាស្សាឈូសេត (NMCOG) ផ្តល់សេវាកម្ម និងដំណើរការកម្មវិធី និងសកម្មភាពទាំងអស់ ស្របតាមច្បាប់សហព័ន្ធស្តីពីការបំបាត់ភាពរើសអើង ដែលរួមមានជំពូកទី៦ក្នុងច្បាប់ស្តីពីសិទ្ធប្រជាពលរដ្ឋឆ្នាំ1964 (ជំពូកទី6) ច្បាប់ស្តីពីប្រត្យាស្ថាប័នសិទ្ធឆ្នាំ1987 បញ្ញត្តិ និងលក្ខន្តិកៈផ្សេងៗដែលពាក់ព័ន្ធ។ ជំពូកទី6 ហាមមិនឲមានការរើសអើងក្នុងកម្មវិធីទាំងឡាយណាដែលឧបត្ថម្ភដោយសហព័ន្ធ។ ជំពូកទី6 ទាមទារមិនឲមានការបដិសេធពលរដ្ឋអាមេរិកាំងណាម្នាក់មិនឲចូលរួម ឬមិនផ្តល់ផលប្រយោជន៍ឲ ឬត្រូវបានគេរើសអើង ដោយសារជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត (រួមទាំងកម្រិតភាសាអង់គ្លេសទាប) ក្នុងកម្មវិធី ឬសកម្មភាពណាមួយដែលឧបត្ថម្ភដោយសហព័ន្ធនោះទេ។ ច្បាប់សហព័ន្ធស្តីពីការបំបាត់ភាពរើសអើងដែលពាក់ព័ន្ធ អនុវត្តដោយការិយាល័យរដ្ឋបាលផ្លូវធំរបស់សហព័ន្ធ និងការិយាល័យផ្លូវឆ្លងកាត់របស់សហព័ន្ធ ហាមមិនឲមានការរើសអើងអាយុ ភេទ និងពិការភាព។ កត្តាទាំងបីនេះក៏ត្រូវបានគេរាប់បញ្ចូលផងដែរក្នុងកម្មវិធីទាំងឡាយណា ដែលកំពុងដំណើរការ ស្របតាមជំពូកទី6របស់ NMMPO និងស្របតាមរដ្ឋបាល និងការបកស្រាយរបស់សហព័ន្ធ។ បន្ថែមពីលើនេះទៀត NMMPO ផ្តល់សិទ្ធដល់ បុគ្គលណាដែលមិនសូវចេះភាសាអង់គ្លេសក្នុងការប្រើប្រាស់សេវាកម្ម និងចូលរួមក្នុងសកម្មភាព និងកម្មវិធីទាំងអស់ ទៅតាមគោលនយោបាយ និងសេចក្តីណែនាំរបស់ ក្រសួងគមនាគមន៍នៃសហរដ្ឋអាមេរិក ដែលមានចែងក្នុងសេចក្តីបង្គាប់របស់អគ្គនីតិប្រតិបត្តិ13166។

*<u>ការការពារផលប្រយោជន៍ដោយគ្មានភាពរើសអើងរបស់រដ្ឋ</u>*

NMCOG/NMMPO គោរពច្បាប់ស្តីពីការប្រើប្រាស់ទីសាធារណៈរដ្ឋម៉ាស្សាឈូសេត M.G.L. c 272 §§ 92a, 98, 98a ដែលហាមមិនឲមានការការរើសអើង ការបង្ហាញភាពខុសគ្នា ឬការដាក់កម្រិតលើសិទ្ធប្រើប្រាស់ទីសាធារណៈ ទៅតាម **ជាតិសាសន៍ ពណ៌សម្បុរ ជំនឿសាសនា ដើមកំណើត ភេទ ទំនោរផ្លូវភេទ ពិការភាព ឬពូជពង្ស**នោះទេ។ NMMPO ក៏គោរពតាមសេចក្តីបង្គាប់របស់អភិបាលរដ្ឋ526 ផ្នែកទី4 ដែលតម្រូវឲកម្មវិធី សកម្មភាព និងសេវាកម្មទាំងអស់ដែលដំណើរការ អនុញ្ញាត ឧបត្ថម្ភ ឬកំណត់ដោយរដ្ឋ ឬជាប់កិច្ចសន្យាជាមួយនឹងរដ្ឋ ធ្វើឡើងដោយគ្មានការរើសអើងខុសច្បាប់ លើ**ជាតិសាសន៍ ពណ៌សម្បុរ អាយុ ភេទ ទំនោរផ្លូវភេទ អត្តសញ្ញាណជេនឌឺ ជំនឿ សាសនា ពូជពង្ស ដើមកំណើត ពិការភាព ឋានៈអតីតយុទ្ធជន (រួមទាំងអតីតយុទ្ធជនក្នុងសង្គ្រាមវៀតណាម) ឬប្រវត្តិ**។

*សម្រាប់ព័ត៌មានបន្ថែម*

ប្រសិនបើលោក–អ្នកត្រូវការព័ត៌មានបន្ថែមស្តីពីជំពូកទី៦ និងកាតព្វកិច្ចបំបាត់ភាពមិនរើសអើងរបស់រដ្ឋនិងសហព័ន្ធ សូមទាក់ទង៖

អ្នកឯកទេសលើជំពូកទី6

NMCOG ការិយាល័យសិទ្ធប្រជាពលរដ្ឋ និងភាពចម្រុះ

40 Church Street, Suite 200

Lowell, MA 01852

(978) 454-8021

JHoward@nmcog.org

*សម្រាប់ការដាក់ពាក្យបណ្តឹង*

ប្រសិនបើលោក–អ្នកចង់ដាក់ពាក្យបណ្តឹងអំពីការបំពានលើសិទ្ធកម្មសិទ្ធទី៦ ឬលើច្បាប់ស្តីពីការបំបាត់ភាពរើសអើងរបស់សហព័ន្ធដែលពាក់ព័ន្ធ សូមទាក់ទង អ្នកឯកទេសលើជំពូកទី6 (ខាងលើ) ក្នុងរយៈពេល ១៨០ថ្ងៃរាប់ចាប់ពីថ្ងៃដែលកើតមានសកម្មភាពនោះ។

ប្រសិនបើលោក–អ្នកចង់ដាក់ពាក្យបណ្តឹងអំពីពីការបំពានលើច្បាប់ស្តីពីការប្រើប្រាស់ទីសាធារណៈរដ្ឋម៉ាស្សាឈូសេត សូមទាក់ទងមក គណៈកម្មការប្រឆាំងការរើសអើង រដ្ឋម៉ាស្សាឈូសេត ក្នុងរយៈពេល ៣០០ថ្ងៃរាប់ចាប់ពីថ្ងៃដែលកើតមាន សកម្មភាពនោះ តាមរយៈ៖

គណៈកម្មការប្រឆាំងការរើសអើងរដ្ឋម៉ាស្សាឈូសេត (MCAD)

One Ashburton Place, 6th Floor

Boston, MA 02109

617-994-6000

TTY: 617-994-6196

MASSDOT.CivilRights@state.ma.us